## ទំព័រស្ដីពីប្រទេសកម្ពុជានិងសូចនាករសំខាន់ៗ

### ប្រទេសកម្ពុជា



| | |
|---|---|
| ចំនួនប្រជាជន | 15,1 លាននាក់ |
| កំណើនប្រជាជន | 1,8 ភាគរយ |
| ផសស (គិតលើមូលដ្ឋាន PPP, int'l US$) | 46,0 ពាន់លាន |
| ផសសក្នុងពលរដ្ឋម្នាក់ (គិតលើមូលដ្ឋាន PPP, int'l US$) | 3,042 |
| ផ្ទៃដីសរុប | 181,040 គ.ម២ |
| រាជធានី | ភ្នំពេញ |

*ប្រភព: World Development Indicators.*

## ខ្លឹមសារសង្ខេប

**ទោះបីជាមានភាពមិនប្រាកដប្រជាក្នុងស្រុកនិងមានអស្ថិរភាពនៅក្នុងប្រទេសជិតខាងក្ដី កម្ពុជានៅតែរក្សាបានកំណើនខ្ពស់។** កំណើនពិតសម្រាប់ឆ្នាំ 2014 ត្រូវបានគេប៉ាន់ស្មានថានឹងឡើងដល់ 7,2 ភាគរយ នាំមុខដោយវិស័យកាត់ដេរ សំណង់ និងសេវាកម្ម។ ជារួម ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចមានលក្ខណៈល្អប្រសើរ ជាមួយនឹងការពង្រឹងផ្នែកសារពើពន្ធ តាមរយៈការលើកកម្ពស់ការគ្រប់គ្រងចំណូល។ ជាមួយនឹងក្ដីរំពឹងនៃការមានទំនុកចិត្តសាជាថ្មី និងការវិលត្រឡប់មកវិញនៃស្ថិរភាពនយោបាយ បន្ទាប់ពីបានបញ្ចប់ភាពជាប់គាំងនយោបាយ រយៈពេលប្រហែលមួយឆ្នាំ កាលពីខែកក្កដា ឆ្នាំ 2014 ទ្រទ្រង់ដោយការពង្រឹងសេដ្ឋកិច្ចពិភពលោក អត្រាកំណើនពិតនៃសេដ្ឋកិច្ចប្រទេសកម្ពុជាសម្រាប់ឆ្នាំ 2015 ត្រូវបានគេរំពឹងថានឹងមានភាពប្រសើរឡើងបន្ថែមទៀត ឈានដល់ 7,5 ភាគរយ។ ហានិភ័យដែលប៉ះពាល់ដល់កំណើនដែលបានព្យាករណ៍នេះគឺលទ្ធភាពនៃការកើតមានភាពរឹតត្បិតផ្នែកពលកម្មទៀត និងទឹកជំនន់នៅរដូវកាលលិចលង់ខ្លាំង ព្រមទាំងភាពមិនប្រាកដប្រជាផ្នែកនយោបាយក្នុងតំបន់ផងដែរ។

## ស្ថានភាពអភិវឌ្ឍសេដ្ឋកិច្ចកន្លងទៅថ្មីៗ

**វិស័យកាត់ដេរសម្លៀកបំពាក់ជាក្បាលម៉ាស៊ីនចំបងក្នុងការជម្រុញកំណើនសេដ្ឋកិច្ច ខណៈវិស័យសំណង់មានការរីកចម្រើនជាងវិស័យទេសចរណ៍ និងវិស័យដំណាំ ដែលមានកំណើនយឺត ហេតុដូចនេះហើយវិស័យសំណង់ជាកត្តាជម្រុញកំណើនសេដ្ឋកិច្ចសំខាន់បំផុតលំដាប់ទីពីរ។** ត្រឹមពាក់កណ្តាលឆ្នាំ 2014 វិស័យកាត់ដេរសម្លៀកបំពាក់បានរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ចំនួន 14,1 ភាគរយ ដោយសារបរិយាកាសប្រសើរឡើងនៃសេដ្ឋកិច្ចសាកល និងការកើនឡើងនៃស្ថេរភាពទីផ្សារការងារ។ វិស័យសំណង់មានសន្ទុះកើនឡើង មានទំនុកចិត្តក្នុងស្រុកសាជាថ្មី មានសន្ទុះលឿនជាងវិស័យទេសចរណ៍ និងវិស័យដាំដុះ។ កំណើនវិស័យសេវាកម្មនៅតែរឹងមាំទោះបីជាអត្រាកំណើននៃការមកដល់នៃភ្ញៀវទេសចរមានល្បឿនយឺតធៀបនឹងឆ្នាំមុនមានអត្រាត្រឹមតែ 5.2 ភាគរយឆ្នាំធៀបនឹងឆ្នាំ ប៉ុណ្ណោះក្នុងរយៈពេលប្រាំមួយខែដើមឆ្នាំ បណ្តាលមកពីភាពវឹកវរផ្នែកនយោបាយនៅប្រទេសថៃដែលនៅក្បែរខាងកម្ពុជា និងភាពតានតឹងរវាងប្រទេសវៀតណាមនិងប្រទេសចិន។ វិស័យកសិកម្មមានកំណើនយឺតដោយសារការធ្លាក់ចុះតម្លៃទំនិញកសិកម្ម។

**ការកាត់បន្ថយភាពក្រីក្រនៅមានជាបន្តដោយសារកំណើនខ្ពស់ ប៉ុន្តែមានល្បឿនទាបជាងមុន។** អត្រាភាពក្រីក្របានធ្លាក់ចុះដល់ 18.6 ភាគរយ នៅឆ្នាំ 2012 ពោលគឺធ្លាក់ចុះ 1.9 ភាគរយ ធៀបនឹងអត្រាភាពក្រីក្រនៅឆ្នាំ 2011។ ទោះជាយ៉ាងណាក្តី ការកាត់បន្ថយភាពក្រីក្រនៅឆ្នាំ 2011-12 មានល្បឿនយឺតជាងអំឡុងឆ្នាំ 2004-11 ក្នុងអំឡុងពេលនោះភាពក្រីក្រធ្លាក់ចុះ ចំនួន 4.7 ភាគរយ ក្នុងមួយឆ្នាំ ដោយសារអង្ករឡើងថ្លៃ ហើយសភាពការណ៍នេះបានជួយដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ។

**កំណើនសេដ្ឋកិច្ចដែលបន្តមានលក្ខណៈល្អប្រសើរនៅឆ្នាំនេះគឺ ត្រូវបានទ្រទ្រង់ដោយលទ្ធផលអនុវត្តនៃ វិស័យទូទាត់ក្រៅប្រទេសដែលមានស្ថេរភាព ទ្រទ្រង់ដោយកំណើននៃវំហូរវិនិយោគផ្ទាល់ពី បរទេស ដែលជួយផ្តល់ហិរញ្ញប្បទានយ៉ាងច្រើនចំពោះឱនភាពគណនីចរន្តដែលមានទំហំធំជាងមុនបន្តិច វិស័យនេះកំពុងរួមចំណែកក្នុងការបង្កើនប្រាក់បម្រុងបរទេស។** ការនាំចេញ សម្លៀកបំពាក់នៅមានកំណើនជាបន្ត ខណៈដែលវំហូរវិនិយោគផ្ទាល់ពីបរទេសកំពុងកើនឡើង ដោយសារទីផ្សារការងារមានស្ថិរភាពសាជាថ្មី និងដោយសារការកើតមានមហិច្ឆតាជាថ្មីរបស់វិនិយោគិនចំពោះវិស័យសំណង់ និងអចលនទ្រព្យ ទាំងនេះធ្វើឱ្យការនាំចូលសម្ភារៈសំណង់កើនឡើង ។ គ្រឿងឧបភោគបរិភោគនាំចូលក៏បានកើនឡើងផងដែរ

ភាគច្រើនគឺការនាំចូលរថយន្ត និងផលិតផលប្រេង។ ឱនភាពគណនីចរន្តត្រូវបានព្យាករថា នឹងកើនឡើងដល់ 11,3 ភាគរយនៃ ផសស មានទំហំធំជាងការព្យាករសម្រាប់ឆ្នាំ 2013 ដែលស្មើ 10.7 ភាគរយ ដែលឱនភាពមួយផ្នែកធំបានទទួលហិរញ្ញប្បទានពីវិនិយោគផ្ទាល់ពីបរទេស។ ដូច្នេះ ទុនបម្រុងអន្តរជាតិសរុបដុលបានកើនពី 3,6 ពាន់លានដុល្លារ ឬពីការនាំចូល 3.4 ខែ នៅចុងឆ្នាំ 2013 ដល់ 4,2 ពាន់លានដុល្លារអាមេរិក ឬការនាំចូលដែលមានរយៈពេល 3.5 ខែ នៅពាក់ កណ្តាលឆ្នាំ 2014។

**បើទោះបីជាអតិផរណាបានកើនឡើងបន្តិចក្តី ស្ថេរភាពថ្លៃនៅតែស្ថិតក្នុងកម្រិតដែលអាចទទួលបានក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងទ្រទ្រង់ការកាត់បន្ថយភាពក្រីក្រ។** នៅពាក់កណ្តាលឆ្នាំ 2014 អតិផរណាបានកើនដល់ 4.9 ភាគរយ ក្នុងមួយឆ្នាំ ធៀបនឹងឆ្នាំមុន ខ្ពស់ជាងចុងឆ្នាំ 2013 ដែលអតិផរណាមានកម្រិតស្មើនឹង 4.6 ភាគរយ។ ថ្លៃទំនិញម្ហូបអាហារភាគច្រើននៅមានស្ថិរភាព ទោះបីជាមានទំនិញអាហារខ្លះ ដូចជា សាច់សត្វ និងទំនិញមិនមែនស្បៀង ជាអាទិ៍ ថ្លៃសេវាសាធារណៈកំពុងកើនឡើងជាបន្តបន្ទាប់ក្តី។ អតិផរណាក្នុងតំបន់ និងអតិផរណាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតនៅមានកម្រិតទាប។

**កំណើនប្រាក់បញ្ញើវិស័យឯកជនបានកើនឡើងយ៉ាងឆាប់រហ័សដោយសារការមានទំនុកចិត្តសាជាថ្មីមកលើសេដ្ឋកិច្ច រួមចំណែកដល់ការបង្កើនស្ថិរភាពក្នុងវិស័យធនាគារ។** នៅពាក់កណ្តាលឆ្នាំ 2014 ប្រាក់បញ្ញើវិស័យឯកជនបានកើនឡើងយ៉ាងខ្ពស់ ឡើងដល់ 8.09 ពាន់លានដុល្លារអាមេរិក ឬកើនឡើង 22.2 ភាគរយ ធៀបនឹងឆ្នាំមុន ខណៈដែលកំណើននេះស្មើនឹង 6.88 ពាន់លានដុល្លារអាមេរិក ឬកើនឡើង 14.2 ភាគរយនៅចុងឆ្នាំ 2013។ ទន្ទឹមនឹងនេះដែរ កំណើនឥណទានបានសំរួលបន្តិច ធ្លាក់ចុះពី 26.7 ភាគរយ មកត្រឹម 21.8 ភាគរយ ធៀបនឹងឆ្នាំមុន ក្នុងរយៈពេលដូចគ្នា។ កំណើនប្រាក់បញ្ញើកើនឡើងជាមួយនឹងកំណើនឥណទានធ្លាក់ចុះធ្វើឲ្យអនុបាតប្រាក់កម្ចីធៀបនឹងប្រាក់បញ្ញើថយចុះពី 90 ភាគរយនៅចុងឆ្នាំ2013 មកត្រឹម 82.2 ភាគរយ នៅពាក់ កណ្តាលឆ្នាំ 2014 ។ អត្រាខ្ចីប្រាក់រយៈពេលខ្លីធ្លាក់ចុះបន្តិច គឺធ្លាក់ចុះពី 11.3 ភាគរយ នៅចុងឆ្នាំ 2013 មកត្រឹម 11.2 ភាគរយ នៅខែ មេសា ឆ្នាំ 2014 ដោយសារការប្រកួតប្រជែងខ្លាំងក្លា រវាងធនាគារនិងធនាគារ។

**ប្រាក់រៀលមានស្ថេរភាពក្នុងរង្វង់ប្រមាណជា 4,000 រៀលក្នុងមួយដុល្លារអាមេរិក ដោយសារគោលនយោបាយគ្រប់គ្រងអត្រាប្តូរប្រាក់គោលដៅ។** នៅពាក់កណ្តាលឆ្នាំ 2014 ប្រាក់រៀលឡើងដល់ 4,040 រៀលក្នុងមួយដុល្លារអាមេរិក ធៀបនឹង 3,995 កាលពីចុងឆ្នាំមុន។ អត្រាប្តូរ

ប្រាក់ដែលកំណត់គោលដៅ ប្រមាណជា 4,000 រៀលក្នុងមួយដុល្លារអាមេរិក ធ្វើឲ្យតម្លៃអត្រាប្តូរប្រាក់ពិតរបស់ប្រាក់រៀលឡើងថ្លៃបន្តិចដោយសារប្រាក់ដុល្លារឡើងថ្លៃធៀបនឹងរូបិយបណ្ណសំខាន់ៗមួយចំនួន ដូចជា ប្រាក់អឺរ៉ូ ប្រាក់យ៉ាន់ ដែលជារូបិយបណ្ណរបស់ដៃគូពាណិជ្ជកម្មចម្បងរបស់កម្ពុជាផងដែរ។

**លទ្ធផលអនុវត្តផ្នែកសារពើពន្ធត្រូវបានពង្រឹងបន្ថែមដោយសារការបង្កើនការគ្រប់គ្រង់ចំណូល ការផ្តល់ហិរញ្ញប្បទានបន្ថែមដើម្បីគាំទ្រការកើនឡើងនូវចំណាយសាធារណៈដោយមិនធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ឱនភាពសារពើពន្ធជារួម (គិតទាំងជំនួយឥតសំណងផងដែរ) ត្រូវបានព្យាករណ៍ថានឹងថយចុះពី 2.7 ភាគរយ នៅឆ្នាំ 2013 ដល់ 2.5 ភាគរយ នៃ ផសស នៅឆ្នាំ 2014។ ស្ថានភាពប្រសើរឡើងនេះគឺដោយសារការបង្កើនការប្រមូលប្រាក់ចំណូលដែលបានកើនឡើងយ៉ាងឆាប់រហ័ស ពោលគឺកើនឡើងចំនួន 21 ភាគរយ ក្នុងរយៈពេលបួនខែដើមឆ្នាំ រីឯចំណាយវិញ កាលពីដំបូងមានល្បឿនយឺត និងទំនងជាស្ថិតក្នុងរង្វង់បរិមាណទឹកប្រាក់ដែលបានគ្រោងក្នុងថវិការ។ ឱនភាពនេះនៅតែបន្តពឹងផ្អែកមួយផ្នែកធំលើហិរញ្ញប្បទានពីបរទេស។ អាស្រ័យហេតុនេះ ប្រាក់សន្សំរបស់រដ្ឋាភិបាលបានកើនឡើងពី 700 លានដុល្លានៅចុង ឆ្នាំ 2013ដល់ 931 លានដុល្លារនៅពាក់កណ្តាលឆ្នាំ 2014។ តាមការវាយតម្លៃរួមគ្នាអំពីការវិភាគនិរន្តរភាពបំណុលរវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ នៅឆ្នាំ 2013 ចំណាត់ថ្នាក់ភាពតឹងតែងនៃបំណុលនៅតែមានកម្រិតទាប ។

## ស្ថានភាពអនាគតនិងបញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ន

**ស្ថានភាពកំណើនក្នុងពេលអនាគតហាក់មានភាពល្អប្រសើរដោយសារស្ថិរភាពនយោបាយក្នុងស្រុក ការងើបឡើងវិញនៃសេដ្ឋកិច្ចនៅអាមេរិក និងស្ថិរភាពនៅប្រទេសថៃ ទាំងអស់នេះគាំទ្រកំណើន ផសស ឲ្យឡើងដល់ 7.5 ភាគរយ នៅឆ្នាំ 2015 ប្រហាក់ប្រហែលនៅឆ្នាំ 2013 ដែរ។** តទៅមុខ ការនាំចេញចម្លៀកបំពាក់នៅតែមានភាពវិជ្ជមាន ចំណែកឯវិស័យសំណង់ និងសេវាកម្មវិញក៏ត្រូវបានរំពឹងថាមានសកម្មភាពរស់រវើកផងដែរ ក៏ដូចជាការងើបឡើងវិញនៃវិស័យទេសចរណ៍ដោយសារនៅប្រទេសថៃមានស្ថេរភាពប្រសើរជាងមុន។ ទោះជាយ៉ាងណាក្តី កំណើនវិស័យកសិកម្មទំនងជានឹងបន្តរងផលប៉ះពាល់ដោយសារការធ្លាក់ថ្លៃទំនិញកសិកម្មនៅលើទីផ្សារអន្តរជាតិ។

**ទោះជាយ៉ាងណាក្តី កំណើនដែលបានព្យាករនេះមានហានិភ័យដែលនាំឲ្យខាតបង់។** ហានិភ័យទាំងនោះ រួមមាន លទ្ធភាពនៃការកើតមានជាថ្មីនូវភាពរឹករផ្ទៃកពលកម្ម ទឹកជំនន់នៅ

រដូវវស្សា ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងធំលើសពីធម្មតាមកលើផលដំណាំ មួយផ្នែកបណ្តាលមកពី លំអានធាតុអាកាសអែលនីណូ(ក្តៅហើយសើម) ការបន្តធ្លាក់ចុះថ្លៃអង្ករបន្ថែមទៀត ជាមួយនឹងការបន្តនាំចេញអង្ករថៃនៅក្នុងត្រីមាសទីបីឆ្នាំនេះ ព្រមទាំងភាពមិនប្រាកដប្រជាផ្នែកនយោបាយក្នុងតំបន់។

**តើប្រទេសកម្ពុជាអាចរក្សានិងជម្រុញខ្លាំងក្លាបន្ថែមទៀតនូវកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេច? បញ្ហាប្រឈមចំបងគឺត្រូវជម្រុញវិស័យកសិកម្មនិងវិស័យទេសចរណ៍ជាថ្មីម្តងទៀត។** ផលិតកម្មស្រូវបានបន្ថយល្បឿនចាប់តាំងពីឆ្នាំ2012មក និងដោយសារដីមានកម្រិត ពីពេលនេះទៅការងើបឡើងវិញនៃវិស័យនេះនឹងអាស្រ័យកាន់តែច្រើនលើការបង្កើនផលិតភាពកសិកម្ម និងបង្កើនគុណភាព ជាជាងការពង្រីកផ្ទៃដី។ វិធានការសម្រាប់បង្កើនផលិតភាពកសិកម្ម រួមមាន ការបង្កើនការវិនិយោគសាធារណៈលើសេវាប្រឹក្សាកសិកម្ម ការអភិវឌ្ឍគ្រាប់ពូជ និងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព-តាមរយៈការលើកកម្ពស់លទ្ធភាពធន់នឹងវិបត្តិ និងបើកទីផ្សារថ្មីៗ នឹងជួយឲ្យវិស័យកសិកម្មមានសន្ទុះឡើងវិញ។ ការកែលម្អការកិនស្រូវនិងថ្លៃចំណាយភស្តុភារនឹងជួយដោះស្រាយបាននូវមូលហេតុចំបងពីរ ដែលធ្វើឲ្យកម្ពុជាបាត់បង់ភាពប្រកួតប្រជែង ដែលកម្ពុជាមានចំពោះថ្លៃក្រោយការប្រមូលផល។ ការបង្កើនលទ្ធភាពឲ្យអ្នកផលិតស្រូវនិងម្ចាស់ម៉ាស៊ីនកិនស្រូវបានទទួលហិរញ្ញប្បទាន ព្រមទាំងការកាត់បន្ថយចំណាយធុរកិច្ចនឹងជួយបង្កើនបរិមាណស្រូវកិននិងកាត់បន្ថយថ្លៃដើមក្នុងការកិនស្រូវ។ ការកែលម្អភស្តុភារ ក៏មុខជាបង្កើនភាពប្រកួតប្រជែងនៃផលិតកម្មកសិកម្មផងដែរ ចំណែកឯការ នាំចេញជួយកម្ពុជាឲ្យអាចសម្រេចបានជិតដល់ផែនការដែលកំណត់អោយបានមួយលានតោន។ ការកែលម្អការដឹកជញ្ជូនជើងគោករួមជាមួយការបង្កើនការសម្របសម្រួលកិច្ចប្រឹងប្រែងរវាងរដ្ឋាភិបាល និងអាជ្ញាធរ មូលដ្ឋាន វិស័យឯកជននិងសហគមន៍មូលដ្ឋាន នឹងជួយជម្រុញពិពិធកម្មគោលដៅទេសចរក្រៅពីឧទ្យានអង្គរ។

**ការជម្រុញកំណើននៃវិស័យកម្មន្តសាលក៏មានសារសំខាន់ក្នុងការរក្សា និងជម្រុញសន្ទុះកំណើនសេដ្ឋកិច្ចផងដែរ។** អង្កេតសហគ្រាសចុងក្រោយនៃការវាយតម្លៃបរិយាកាសវិនិយោគក្នុងពេលខាងមុខបង្ហាញថា បរិយាកាសវិនិយោគធុរកិច្ចបន្តរារាំងភាពប្រកួតប្រជែងរបស់ក្រុមហ៊ុននានានៅកម្ពុជា។ ថ្លៃភ្លើង លទ្ធភាពមានអគ្គិសនីប្រើប្រាស់ ការបង់ថ្លៃក្រៅផ្លូវការ និងកិច្ច

ប្រតិបត្តិនានាដែលគ្មានលក្ខណៈប្រកួតប្រជែងនៅតែជាឧបសគ្គចំបងចំពោះក្រុមហ៊ុន។ អង្កេតនេះក៏បង្ហាញផងដែរថាតំបន់សេដ្ឋកិច្ចពិសេសដែលជាតំបន់ត្រូវផ្តល់បរិយាកាសវិនិយោគល្អប្រសើរ នៅមិនទាន់ផ្តល់អត្ថប្រយោជន៍ដែលវិនិយោគិនបរទេសរំពឹងនៅឡើយទេ។ ហេតុនេះកំណើនសេដ្ឋកិច្ចរឹងមាំក្នុងពេលបច្ចុប្បន្ន គឺជាកាលានុវត្តភាពមួយ សម្រាប់កែលម្អបរិយាកាសធុរកិច្ចតាមរយៈការដោះស្រាយបញ្ហាអគ្គិសនី ដែលមានតម្លៃខ្ពស់ ជាមួយការដេញថ្លៃដែលមាន តម្លាភាព ការបន្តស្វ័យប្រវត្តិកម្មនៃដំណើរការធុរកិច្ច ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ការបង្កើនភាពទាក់ទាញរបស់តំបន់សេដ្ឋកិច្ចពិសេស ការកសាងបញ្ចប់ច្បាប់ស្តីពីការប្រកួតប្រជែងនិងច្បាប់ស្តីពីការវិនិយោគដែលលើកកម្ពស់បរិយាកាសវិនិយោគ និងការសម្រួលការចុះបញ្ជីពាណិជ្ជកម្មមានលក្ខណៈសាមញ្ញ។ ត្រូវបន្តពង្រឹងការនាំចេញតាមរយៈការបង្កើនអត្ថប្រយោជន៍ជាអតិបរមាពីការងើបឡើងវិញនៃសេដ្ឋកិច្ចសាកល ជាមួយគ្នានេះការរក្សា ស្ថិរភាពនយោបាយ នឹងឈានទៅសម្រេចបានដំណើរការមួយដែលបញ្ចប់ភាពមន្ទិល និងមានតម្លាភាពនៅក្នុងការចរចាប្រាក់ឈ្នួលអប្បរមាបីភាគី ចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ ។ ការធ្វើបែបនេះក៏នឹងជួយទាក់ទាញការផ្លាស់ប្តូរទីតាំងនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសបន្ថែមទៀតពីបណ្តាប្រទេសរីកចម្រើននានានៅក្នុងតំបន់ផងដែរ។

**ការធានាស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុតាមរយៈការលើកកម្ពស់ការត្រួតពិនិត្យនឹងជួយបង្ការភាពផុយស្រួយក្នុងវិស័យសំណង់និងអចលនទ្រព្យ**ជាមួយគ្នានេះក៏ពង្រឹងភាពធន់របស់កម្ពុជាក្នុងការប្រឈមមុខនឹងភាពប្រែប្រួលខ្លាំងជាងនេះនៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិផងដែរ។

**ជាទូទៅ ការបង្កើនវិនិយោគផ្នែកមូលធន ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ ការលើកកម្ពស់ការអប់រំក្នុងប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈនឹងជួយប្រទេសកម្ពុជាឲ្យវិលមកកាន់មាគ៌ាកំណើនកាន់តែខ្ពស់។** ការពង្រីកមូលដ្ឋានគិតពន្ធបន្ថែមនិងការពង្រឹងរដ្ឋបាលពន្ធនឹងជួយផ្តល់ហិរញ្ញប្បទានលើការចំណាយអភិវឌ្ឍន៍ដែលមានតម្រូវការយ៉ាងច្រើន។ ការអនុវត្តកំណែទម្រង់ដោយជោគជ័យនឹងជួយបង្កើនវិនិយោគបន្ថែមប្រមាណជា ៥ ភាគរយ នៃ ផសស និងអនុញ្ញាតឲ្យប្រទេសកម្ពុជាសម្រេចបានមាគ៌ាកំណើន ផសស លើស ៨ ភាគរយ។

**ការកសាងរបៀបវារៈកំណែទម្រង់ជាក់ច្បាស់អមដោយមុខសញ្ញានៃកំណែទម្រង់អាទិភាព និង មានក្របខណ្ឌតាមដានរឹងមាំនឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តរបស់រដ្ឋាភិបាល។**

យុទ្ធសាស្ត្រចតុកោណរយៈពេលប្រាំឆ្នាំថ្មី ដំណាក់កាលទី III របស់រាជរដ្ឋាភិបាលកម្ពុជាកំណត់ច្បាស់នូវបញ្ហាប្រឈម និងអាទិភាពនៃការអភិវឌ្ឍសម្រាប់កម្ពុជា។ ការបង្កើតផែនការសកម្មភាពលម្អិតដែលមានទំនាក់ទំនងជាមួយបណ្តាអាទិភាពនានា និងការបង្កើតប្រព័ន្ធតាមដានរឹងមាំ ដើម្បីពិនិត្យមើលលទ្ធផលអនុវត្តន៍ជាទៀងទាត់ នឹងជួយប្រទេសកម្ពុជាដោះស្រាយបាននូវបញ្ហាប្រឈមនៃការអភិវឌ្ឍនិងឆ្លើយតបនឹងអាទិភាពនានារបស់កម្ពុជាកាន់តែមានប្រសិទ្ធភាព។

# កម្ពុជា: សូចនាករសំខាន់ៗ

| | ឆ្នាំ 2012 | ឆ្នាំ 2013 | ឆ្នាំ 2014p | ឆ្នាំ 2015f | ឆ្នាំ 2016f |
|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | | |
| ផសស ពិត (% ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 7.3 | 7.4 | 7.2 | 7.5 | 7.2 |
| តម្រូវការក្នុងស្រុក(%ប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | 14.9 | 12.1 | 12.4 | 11.0 | 10.7 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (%ប្រែប្រួលចុងគ្រា) | 2.5 | 4.6 | 5.0 | 5.5 | 6.0 |
| **វិស័យសាធារណៈ** | | | | | |
| ចំណូលរដ្ឋាភិបាល (% នៃផសស) | 15.3 | 15.1 | 16.1 | 16.4 | 16.4 |
| ចំណាយរដ្ឋាភិបាល(% នៃផសស) | 21.0 | 21.5 | 20.4 | 20.9 | 21.3 |
| តុល្យការរដ្ឋាភិបាលមិនគិតជំនួយឥតសំណង (% នៃផសស) | -5.7 | -6.4 | -4.3 | -4.5 | -4.9 |
| តុល្យការរដ្ឋាភិបាលគិតទាំងជំនួយឥតសំណង (% នៃផសស) | -3.3 | -2.7 | -2.5 | -3.5 | -3.3 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងពាណិជ្ជកម្ម និងបំណុលបរទេស** | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លារអាមេរិក) | -2,455.7 | -2,598.4 | -2,908.3 | -2,955.7 | -2,856.1 |
| នាំចេញទំនិញ (លានដុល្លារអាមេរិក) | 5,632.8 | 6,890.2 | 8,193.4 | 9,700.2 | 11,571.6 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.9 | 22.3 | 18.9 | 18.4 | 19.3 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) 1/ | 7.0 | 17.6 | 15.0 | 15.5 | 15.0 |
| ការនាំចូលទំនិញ (លានដុល្លារអាមេរិក) | 8,088.5 | 9,488.6 | 11,101.7 | 12,655.9 | 14,427.7 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 20.6 | 17.3 | 17.0 | 14.0 | 14.0 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,366.0 | -1,639.0 | -1,849.1 | -1,989.0 | -1,834.0 |
| (% នៃផសស) | -9.6 | -10.7 | -11.3 | -11.2 | -9.6 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | 1,404.8 | 1,298.8 | 1,380.0 | 1,400.0 | 1,450.0 |
| បំណុលបរទេស (លានដុល្លារអាមេរិក) | 4,559.3 | 5,124.1 | 5,630.6 | 6,019.1 | 6,380.5 |
| (% នៃផសស) | 32.1 | 33.3 | 34.4 | 33.9 | 33.3 |
| បំណុលរយៈពេលខ្លី (លានដុល្លារអាមេរិក) | - | - | - | - | - |
| អនុបាតសេវាបំណុល (% ការនាំចេញទំនិញនិងសេវា) | 1.1 | 1.1 | 1.2 | 1.1 | 1.3 |
| ទុនបំរុងជារូបិយបណ្ណបរទេសដុល(លានដុល្លារអាមេរិក) | 3,463.0 | 3,642.5 | 4,300.0 | 4,600.0 | 5,100.0 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | 3.1 | 3.4 | 3.5 | 3.3 | 3.2 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 29.6 | 26.7 | 20.0 | 19.5 | 18.0 |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | 11.6 | 11.3 | 11.2 | 11.0 | 11.0 |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាមេរិក ចុងគ្រា) | 3,995.0 | 3,995.0 | 4,065.0 | 4,076.0 | 4,050.0 |
| អត្រាប្តូរប្រាក់ខ្ទែងពិត(ឆ្នាំ2000=100) | 105.4 | 109.9 | 112.1 | 113.5 | 115.5 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 0.5 | 4.3 | 2.0 | 1.3 | 1.7 |
| អនុស្សារណៈ ផសសជាក់ស្តែង(លានដុល្លារអាមេរិក) | 14,188 | 15,373 | 16,367 | 17,759 | 19,173 |

ប្រភព:ប្រភពទិន្នន័យជាតិ អង្គការមូលនិធិរូបីយវត្ថុអន្តរជាតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

f = ព្យាករណ៍

p = ព្យាករណ៍ (គណនា)

1/ វិស័យកាត់ដេរ

2/ មិនគិតបង្វែរផ្លូវការ